# ឯកសារសង្ខេបអំពីដៃគូអនុវត្តយុទ្ធសាស្ត្រ ផ្នែកអំពើហិង្សាទាក់ទងនឹងយេនឌ័រ

## សង្ខេបគម្រោង

សម្រាប់កម្មវិធី ACCESS ក្នុងដំណាក់កាលទី២ អង្គការធីភីអូ នឹងបន្តធ្វើការផ្តោតលើការកសាងសមត្ថភាពរបស់អ្នកផ្តល់សេវាថ្នាក់មូលដ្ឋាន ក្នុងការផ្តល់សេវាគាំទ្រចិត្តសង្គមដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងយេនឌ័រ នៅក្នុងស្រុកគោលដៅចំនួន៥ គឺ៖ ស្រុកស្ទឹងត្រង់ ពួក ក្រឡាញ់ លំផាត់ និងស្រុកអូរយ៉ាដាវ។ វគ្គបណ្តុះបណ្តាលទាំងនេះរួមមាន វគ្គបណ្តុះបណ្តាលស្តីពី បទដ្ឋានអប្បបរមាសម្រាប់ការផ្តល់ប្រឹក្សាជាមូលដ្ឋានដល់ស្ត្រី និងក្មេងស្រីដែលរងគ្រោះដោយអំពើហិង្សាទាក់ទងយេនឌ័រ វគ្គបណ្តុះបណ្តាលគាំទ្រផ្លូវចិត្តបឋម និងប្រធានបទទាក់ទងនឹងសុខភាពផ្លូវចិត្តផ្សេងទៀត វគ្គរំលឹក និងសកម្មភាពអភិបាលកិច្ច ក៏ត្រូវរៀបចំឡើងដើម្បីពង្រឹងចំណេះដឹង និងជំនាញក្នុងចំណោមអ្នកផ្តល់សេវាផងដែរ។ ជាងនេះទៀត កិច្ចសហការរវាងដៃគូអនុវត្តគម្រោងផ្សេងទៀត រួមមាន សមាគមន៍ និងស្ថាប័ននានាដែលផ្តល់សេវាផ្តោតលើជនជាតិដើមភាគតិច និងជនមានពិការភាព ក៏នឹងត្រូវបានពង្រឹង និងផ្តោតការយកចិត្តទុកដាក់បន្ថែមក្នុងគោលបំណងដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ជនរងគ្រោះ។

## លទ្ធផលរំពឹងទុករបស់គម្រោង

លទ្ធផលរំពឹកទុកទី១៖ ការពង្រឹងគុណភាពនៃការផ្តល់សេវាគាំទ្រចិត្តសង្គម ដល់ជនរងគ្រោះមាន និងមិនមានពិការភាព ដែលរងគ្រោះដោយអំពើហិង្សាទាក់ទងយេនឌ័រ តាមរយៈការបណ្តុះបណ្តាល និងការផ្តល់អភិបាលកិច្ចបច្ចេកទេស ដល់អ្នកផ្តល់សេវាថ្នាក់មូលដ្ឋាន។

លទ្ធផលរំពឹងទុកទី២៖ ជនរងគ្រោះដោយអំពើហិង្សាទាក់ទងយេនឌ័រ នៅក្នុងស្រុកគោលដៅ ត្រូវបានបញ្ជូនទៅរកសេវាសមស្រប និងទាន់ពេលវេលា។

## សកម្មភាពសំខាន់ៗ

១. ផ្តល់វគ្គបណ្តុះបណ្តាលអំពីបទដ្ឋានអប្បបរមាសម្រាប់ការផ្តល់ប្រឹក្សាជាមូលដ្ឋានដល់ស្ត្រី និងក្មេងស្រីដែរងគ្រោះដោយអំពើហិង្សាទាក់ទងយេនឌ័រ និងប្រធានបទផ្សេងទៀតទាក់ទងនឹងសុខភាពផ្លូវចិត្ត និងអំពើហិង្សាទាក់ទងយេនឌ័រ។

| |
|---|
| ២. ផ្តល់វគ្គរំលឹក និងអភិបាលកិច្ចបច្ចេកទេស ដល់អ្នកផ្តល់សេវានៅក្នុងតំបន់គោលដៅថ្មី និងតំបន់គោលដៅចាស់ ដើម្បីបន្តផ្តល់ការគាំទ្រចិត្តសង្គមដែលមានគុណភាពដល់ជនរងគ្រោះ។<br>៣. គាំទ្រដល់ស្រុកមួយចំនួនក្នុងការរៀបចំបន្ទប់ប្រឹក្សាយោបល់គំរូ។<br>៤. ផ្សព្វផ្សាយចំណេះដឹង និងអប់រំផ្លូវចិត្តដល់ប្រជាពលរដ្ឋក្នុងសហគមន៍អំពីអំពើហិង្សា និងផលប៉ះពាល់ដល់សុខភាពផ្លូវចិត្ត របៀបកំណត់រកអ្នកដែលកំពុងមានបញ្ហាចិត្តសង្គមដែលកំពុងត្រូវការសេវាគាំទ្រ និងសេវាគាំទ្រដែលអាចរកបានសម្រាប់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងយេនឌ័រ។<br>៥. អន្តរាគមន៍បែបប្រឹក្សាយោបល់ផ្លូវចិត្ត និងការព្យាបាលជំងឺផ្លូវចិត្ត ដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងយេនឌ័រ (អន្តរាគមន៍ដោយជួបមុខផ្ទាល់ និងអន្តរាគមន៍ពីចំងាយ)។<br>៦. ចូលរួមស្វែងរកការគាំទ្រមតិសម្រាប់ការពង្រឹងគុណភាពនៃការផ្តល់សេវាគាំទ្រចិត្តសង្គមដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងយេនឌ័រ តាមរយៈការចូលរួមក្នុងកិច្ចប្រជុំនានា ដូចជា កិច្ចប្រជុំក្រុមការងារបច្ចេកទេសឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ កិច្ចប្រជុំជាមួយបណ្តាញក្រុមការងារផ្នែកអំពើហិង្សាទាក់ទងនឹងយេនឌ័រ (ថ្នាក់ខេត្ត និងថ្នាក់ស្រុក) យុទ្ធនាការ១៦ថ្ងៃបញ្ឈប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី និងកិច្ចប្រជុំប្រចាំឆមាសសម្រាប់ថ្នាក់ខេត្តជាដើម។ |
| **អ្នកទទួលផល** |
| • អ្នកផ្តល់សេវាថ្នាក់មូលដ្ឋាន ចំនួន១៨០នាក់នឹងទទួលបានការបណ្តុះបណ្តាល បង្វឹកអំពីបទដ្ឋានអប្បបរមាសម្រាប់ការប្រឹក្សាជាមូលដ្ឋាន និងការផ្តល់សេវាគាំទ្រចិត្តសង្គមដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងយេនឌ័រ។<br>• ស្ត្រីនិងក្មេងស្រីចំនួន ៥០០ករណី បានទទួលសេវាគាំទ្រចិត្តសង្គមពីសំណាក់អ្នកផ្តល់សេវាថ្នាក់មូលដ្ឋាន និងពីសំណាក់បុគ្គលិកគម្រោង។<br>• ស្ត្រី និង ក្មេងស្រីចំនួន ១០០០ករណី បានចូលរួមក្នុងការអប់រំផ្លូវចិត្តនៅក្នុងសហគមន៍ អំពីប្រធានបទទាក់ទងនឹងសុខភាពផ្លូវចិត្ត និងសេវាពាក់ព័ន្ធផ្សេងទៀត។ |
| **តំបន់គោលដៅ** |
| • ខេត្តកំពង់ចាម៖ ស្រុកស្ទឹងត្រង់<br>• ខេត្តសៀមរាប៖ ស្រុកពួក និង ស្រុកក្រឡាញ់<br>• ខេត្តរតនគិរី៖ ស្រុកលំផាត់ និង ស្រុកអូយ៉ាដាវ |
| **ដៃគូអនុវត្តគម្រោង** |
| អង្គការ UNFPA  អង្គការ CARE និង ស្ថាប័នក្នុងស្រុកមួយចំនួនដែលធ្វើការទាក់ទងនឹងជនជាតិដើមភាគតិច និងជនមានពិការភាព មន្ទីរកិច្ចការនារីនៅក្នុងខេត្តគោលដៅ។ |

| | |
|---|---|
| **រយៈពេលអនុវត្តគម្រោង** | |
| ពីខែមករា ឆ្នាំ២០២៤ ដល់ ខែមិថុនា ឆ្នាំ២០២៨ | |
| **ព័ត៌មានទំនាក់ទំនង** | |
| អង្គការចិត្តសង្គម អន្តរវប្បធម៌ (TPO)<br>លោកបណ្ឌិត ឈឹម សុធារ៉ា<br>នាយកប្រតិបត្តិ<br>ទូរស័ព្ទលេខ៖ (៨៥៥) ១២ ៦៨៧ ១៨៥<br>អ៊ីម៉ែល៖ sotheara@tpocambodia.org | កម្មវិធី ACCESS 2<br>លោកស្រី ប៊ូ មករា<br>ប្រធានផ្នែកអំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV)<br>ទូរស័ព្ទ៖ (៨៥៥) ១២ ៦៩៤ ៩៩៤<br>អ៊ីម៉ែល៖ makara.bou@access2cambodia.org |

គម្រោងនេះ ឧបត្ថម្ភដោយរដ្ឋាភិបាលអូស្ត្រាលីតាមរយៈកម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជាដើម្បីសេវាប្រកបដោយនិរន្តរភាព និងសមធម៌ - ដំណាក់កាលទី២ (ACCESS 2)។

ខែមីនា ឆ្នាំ២០២៤